**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៥៨
ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩
**សាលដីកា**
លេខ ៦១ IV
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

# សាលដីកា

តាងនាមប្រជាពលរដ្ឋខ្មែរ
តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២.លោក [redacted] ជាចៅក្រម
៣.លោក [redacted] ជាចៅក្រមរបាយការណ៍
៤.លោក [redacted] ជាចៅក្រម
៥.លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted]

**តំណាងមហាអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣០៨ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ ចំពោះសាលដីការបស់សភាស៊ើបសួរសាលាឧទ្ធរណ៍លេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ ដែលមាន៖

ជនត្រូវចោទឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ៥១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តសៀមរាប មេម៉ាយ មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ជាទីតិជន ទោសពីមុនគ្មាន។ (អ្នកប្តឹងសាទុក្ខ)

មេធាវីលោក [redacted] ម៉ៅ និងលោក [redacted] សុជាថា ការពារសិទ្ធិ



Scanned with CamScanner

ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅភូមិបឹងមាលា ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីខែកក្កដា ឆ្នាំ២០១៧ និងខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧, ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឌូច ភេទស្រី អាយុ ៦២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ។

មេធាវីលោក [redacted] ច័ន្ទម៉ានីន ការពារសិទ្ធិ

អំពីអង្គហេតុ

កាលពីខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] ផល្លា បាននិយាយបញ្ចុះបញ្ចូលជនរងគ្រោះ ឈ្មោះ [redacted] វួច ថាឈ្មោះ [redacted] ញ៉ក់ និងឈ្មោះ [redacted] សុភាវ័ន្ត មានដីរាប់រយហិកតាសម្រាប់លក់។ ក្រោយមកជនរងគ្រោះបានមកជួបឈ្មោះ [redacted] ញ៉ក់ និងឈ្មោះ [redacted] សុភាវ័ន្ត តាមការណែនាំរបស់ឈ្មោះ [redacted] ផល្លា នៅការិយាល័យរបស់ជនរងគ្រោះ នៅរាជធានីភ្នំពេញដោយពួកគេបង្ហាញផែនទី និងឯកសារឱ្យជនរងគ្រោះមើល ដោយមានការជឿជាក់ក៏បានចុះកិច្ចសន្យាជាមួយពួកគេជា ០៣ លើក៖

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ជនរងគ្រោះបានចុះកិច្ចសន្យាទិញលក់ដីជាមួយឈ្មោះ [redacted] ញ៉ក់ លើទំហំដី ១០២ ហិកតា ស្ថិតនៅភូមិបឹងមាលា ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តស្វាយរៀង ដោយក្នុង ១ ហិកតា តម្លៃ ៣៣០០ $ (បីពាន់បីរយ) ដុល្លារអាមេរិក សរុបទឹកប្រាក់ចំនួន ៣៣៦៦០០ (សាមសិបបីម៉ឺនប្រាំមួយពាន់ប្រាំមួយរយ) ដុល្លារ លុះដល់ខែមេសា ឆ្នាំ២០១៨ ពួកគាត់បានប្រគល់ឯកសារដី ដោយចុះហត្ថលេខាលោកមេឃុំបឹងមាលា និងចុះរាស់វែងដោយអភិបាលស្រុកស្វាយលើ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ជនរងគ្រោះបានចុះកិច្ចសន្យាទិញលក់ដីជាមួយឈ្មោះ [redacted] ញ៉ក់ លើដីទំហំ ១៧៨ ហិកតា ស្ថិតនៅចំណុចត្រពាំងចំរេះ ភូមិបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ដែលដីខាងលើមានចំនួន ៥៤ ហិកតា ក្នុង ០១ ហិកតាតម្លៃ ៤៣០០ (បួនពាន់បីរយ) ដុល្លារ និងដីខាងក្រោយមានចំនួន ១០២ ហិកតា ក្នុង ១ ហិកតាតម្លៃ ៣១០០ (បីពាន់មួយរយ) ដុល្លារ សរុបទាំងមុខទាំងក្រោយចំនួន ៦០៨ ៥០០ (ប្រាំមួយសែនប្រាំបីពាន់ប្រាំរយ) ដុល្លារ ជនរងគ្រោះប្រគល់ប្រាក់ជាហូរហែរសរុបចំនួន ៥៣៨ ៥០០ (ប្រាំសែនបីម៉ឺនប្រាំបីពាន់ប្រាំរយ) ដុល្លារ នៅសល់ទឹកប្រាក់ចំនួន ៧០ ០០០ (ប្រាំពីរសែន) ដុល្លារ ទៀត។ នៅអំឡុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០១៨ ពួកគាត់បានប្រគល់ឯកសារដីដែលបានចុះហត្ថលេខាលោកមេឃុំបឹងមាលា និងចុះរាស់វែង

Scanned with CamScanner

ដោយភូមិបាលស្រុកស្វាយលើ លើផ្ទៃដីចំនួន ១៥៩ ហិកតា នៅខ្វះចំនួន ១៩ ហិកតាទៀត និងនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ជនរងគ្រោះបានចុះកិច្ចសន្យាទិញលក់ដីជាមួយឈ្មោះ [redacted] ញ៉ាក់ លើទំហំដី ៤១ ហិកតា ស្ថិតនៅចំណុចតាគម ភូមិមាលា ឃុំបឹងមាលា ស្រុកស្វាយលើ ក្នុង ០១ ហិកតា តម្លៃ ៥០០០ (ប្រាំពាន់) ដុល្លារ ស្មើចំនួន ២០៥ ០០០ (ពីរសែនប្រាំពាន់)ដុល្លារ។ ជនរងគ្រោះបានប្រគល់ប្រាក់ចំនួន ៣ លើក សរុបចំនួន ៨០ ០០០ (ប្រាំបីម៉ឺន) ដុល្លារ។ នៅអំឡុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០១៨ ពួកគាត់បានប្រគល់ឯកសារដី ចុះហត្ថលេខាដោយលោកមេឃុំបឹងមាលា និងចុះវាស់វែងដោយអភិបាលស្រុកស្វាយលើ លើឯកសារផ្ទៃដីចំនួន ២៦ ហិកតា នៅខ្វះ ១៥ ហិកតាទៀត។ ក្រោយពីទទួលបានឯកសារដី ជនរងគ្រោះបានជួលគ្រឿងចក្រ ចុះកាយព្រំដីតាមប្លង់ផែនទី ស្រាប់តែប្រជាពលរដ្ឋច្រើនគ្រួសារមកតវ៉ា ថាពួកគាត់ពុំទាន់បានទូទាត់ពីឈ្មោះ [redacted] ញ៉ាក់ និងឈ្មោះ [redacted] សុភាវត្ថិ នៅឡើយ ឯមួយចំនួនទៀតអះអាងបានទទួលរួចហើយ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាបលេខ ១៩៣៧ (ង) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

មិនឱ្យឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ៥១ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅ [redacted] ខេត្តសៀមរាប លំនៅមុនពេលឃុំ [redacted] ខេត្តសៀមរាប មេម៉ាយ មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ស ទោសពីមុនគ្មាន កម្រិតវប្បធម៌រៀនថ្នាក់ទី៧ ។

ដែលត្រូវបានដាក់ក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅភូមិបឹងមាលា ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីខែកក្កដា ឆ្នាំ២០១៧ និងខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំទេ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុជាថា មេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ផល្លា ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៩៣៧ (ង) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុជាថា ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ផល្លា ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្អែកទីផ្នែកគតិច្បាប់។

២.តម្កល់ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៩៣៧ "ង" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល។

៣.សាលដីកានេះ ពិភាក្សាដេញដោលជាអសាធារណៈ និងប្រកាសជាអសាធារណៈ នៅថ្ងៃពុធ ៤ កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ហៃ មេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ផល្លា ប្តឹងមិនសុខចិត្តទៅនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**នាពេលសវនាការ**

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ជនត្រូវចោទ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទឆបោក និងត្រូវបានឃុំខ្លួន កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ដែលរយៈពេលនោះមកដល់បច្ចុប្បន្នឃើញថា មានរយៈពេលលើសពី ៣ ខែ ហើយដែលមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីការឃុំខ្លួនពាក់កណ្តាលអប្បបរមានៃទោស។ តែទោះជាយ៉ាងណា គប្បីសាកសួរបន្ថែមអំពីចំណាក់ការរឿងក្តីនេះ បានទៅដល់នីតិវិធីណាហើយ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ:

១.ធ្វើការសាកសួរបន្ថែម ទៅលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។

Scanned with CamScanner

-ជនត្រូវចោទឈ្មោះ [redacted] ផល្លា បានឆ្លើយថា ខ្លួនប្ដឹងសាទុក្ខមកនេះគឺដោយសារតែខ្លួនមិនមានការពាក់ព័ន្ធក្នុងរឿងក្ដីដែលចោទប្រកាន់ពីបទ ឆបោក ទេ ដោយហេតុថា ខ្លួនគ្រាន់តែបានទំនាក់ទំនងជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ឱ្យទិញដីពីឈ្មោះ [redacted] ញ៉ក់ និងពីឈ្មោះ [redacted] សុភារ័ត្ន ដោយទទួលបានកម្រៃជើងសារ និងបានធ្វើជាសាក្សីក្នុងការទិញលក់ដីរវាងអ្នកលក់ [redacted] ញ៉ក់ និង [redacted] សុភារ័ត្ន ជាមួយអ្នកទិញជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ្នកដែលលក់ដីឱ្យគាត់បានប្រហែលជា ២០ ហាត់ជាង ប៉ុន្តែខ្លួនមិនសូវដឹងច្បាស់នោះទេ ព្រោះខ្លួនគ្រាន់តែជាអ្នកគួរជេរ, មានមនុស្សពីរនាក់ដែលលក់ដីឱ្យឈ្មោះ [redacted] វួច ចំណែកខ្លួនជាសាក្សីឱ្យឈ្មោះ [redacted] វួច នេះ។ ខ្លួនពុំបានដឹងថា ដីដែលលក់នោះមានប៉ុន្មានហិចតាទេ ព្រោះខ្លួនបញ្ជាក់ហើយថា ខ្លួនគ្រាន់តែជាសាក្សីប៉ុណ្ណោះ, ហើយនៅពេលដែលគេប្រគល់នៅនោះ ខ្លួនក៏ធ្វើជាសាក្សីដែរ, ដើមបណ្ដឹងរដ្ឋប្បវេណីមកចោទប្រកាន់ខ្លួនថាឃុបឃិតគ្នានេះ គឺពុំត្រឹមត្រូវនោះទេ ព្រោះខ្លួនគ្រាន់តែចង់បានទូរកាគរយពីឈ្មោះ [redacted] វួច ។ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តា ជួយរកយុត្តិធម៌ និងសុំឱ្យខ្លួនរួចផុតពីការឃុំខ្លួន។

-លោក [redacted] ច័ន្ទម៉ានីន មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វួច បានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ព្រោះជនត្រូវចោទបានកុហកតុលាការ ព្រោះគាត់មិនមែនប្រព្រឹត្តបទល្មើសតែម្ដងនេះទេ តុលាការថ្នាក់ក្រោមបានសម្រេចផ្ដន្ទាទោសគាត់រួចម្ដងហើយ។ ជនត្រូវចោទបានអះអាងប្រាប់កូនក្ដីខ្លួនថា គាត់ពិតជាមានដីលក់ពិតមែន ហើយកូនក្ដីខ្លួនបានដាក់ប្រាក់ ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែពេលដែលចូលទៅឈូសឆាយ វាគ្មានដីទៅវិញ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីកត់សំគាល់របស់ជនត្រូវចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

**សំអាងហេតុ**

១.យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣០៨ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ហៃ មេធាវីការពារសិទ្ធិជនត្រូវចោទ [redacted] ផល្លា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា នៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូលនេះ ជនត្រូវចោទបានលើកឡើងថា ខ្លួនមិនមានការពាក់ព័ន្ធក្នុងរឿងក្ដីដែលចោទប្រកាន់ពីបទ ឆបោក ទេ ដោយហេតុថា ខ្លួនគ្រាន់តែបានទំនាក់ទំនងជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ឱ្យទិញដីពីឈ្មោះ សាត ញ៉ក់ និងពីឈ្មោះ ជ័យ សុភារ័ត្ន ដោយទទួលបានកម្រៃជើងសារ និងបានធ្វើជាសាក្សីក្នុងការទិញលក់ដីរវាងអ្នកលក់ [redacted] ញ៉ក់ និង [redacted] សុភារ័ត្ន ជាមួយអ្នកទិញ ជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ នោះ តុលាការកំពូលពិនិត្យលើការសម្រេចអំពីការមិនដោះលែងឱ្យនៅក្រៅឃុំរបស់សភាស៊ើបសួរ មិនមានកំហុសក្នុងការអនុវត្តច្បាប់នោះទេ។ លើសពីនេះ តាមការកត់សម្គាល់របស់ជនត្រូវចោទ ជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាបចេញដីកាដំណោះស្រាយលេខ ៦៤២៦ (ង) ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ បញ្ជូនទៅជំនុំជម្រះ និងរក្សាទុកជនត្រូវចោទរូបនេះនៅក្នុងឃុំរង់ចាំតុលាការជំនុំជម្រះ ហើយត្រូវបានសាលាដំបូងខេត្តសៀមរាបសម្រេច ផ្ដន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ០១ ឆ្នាំ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ទៀតផង ឃើញថា បណ្ដឹងសាទុក្ខដែលសុំឱ្យដោះលែងជនត្រូវចោទ នៅក្រៅឃុំជាបណ្ដោះអាសន្ន លែងមានប្រយោជន៍ទៀតហើយ។ ដូច្នេះ តុលាការកំពូល មិនមានភាពចាំបាច់ក្នុងពិនិត្យលើការសុំឱ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទឡើយ។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមច្បាប់។

**ហេតុដូច្នេះ**

**សម្រេច**

១.**បដិសេធ** បណ្ដឹងសាទុក្ខលេខ ៣០៨ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ហៃ មេធាវីការពារសិទ្ធិជនត្រូវចោទ [redacted] ផល្លា។

២.**តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ III "ឃ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល។

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ និងប្រកាស ជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner